អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបត់ក្រដាសជារាងគ្រាប់ភ្នែក**

**ចិត្តចលភាព** ៖ **បំណិនចលនាតូចៈ**

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងចលនាភ្នែកៈ

**សិក្សាសង្គម** ៖ **គំនូរនិងសកម្មភាពកសាងៈ**

ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតជារូបភាពៈ

**គោលបំណងៈ**

**ចិត្តចលភាព** ៖ វិជ្ជាសម្បទាៈ

ប្រាប់បានពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយឬលេងល្បែង។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទាៈ បត់ក្រដាសបានជារូបភាពផ្សេងៗៈ យន្តហោះ ទូក អាវ ភ្នែក…
ចរិយាសម្បទាៈ រហ័សរហួន និងប្រុងប្រយ័ត្នក្នុងការការចាប់កាន់ បត់ សូន គូស
ហែក កាត់ និងផាត់ពណ៌។

**កម្រិតសិក្សា** ៖ទាប មធ្យម និង ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាស ខ្មៅដៃ ខ្មៅដៃពណ៌ ប៊ិក កន្ត្រៃ

**ការរៀបចំ** ៖ ក្រដាសស ដីខ្មៅ ដីខ្មៅពណ៌ កន្ត្រៃ

**សេចក្តីណែនាំ** ៖

1. សួរកុមារថា តើកូនៗធ្លាប់លេងទូរសព្ទយូរៗដែរឬទេ? ធ្លាប់
2. កូនៗដឹងទេថា ពេលលេងទូសព្ទយូរៗអីចឹងមានគ្រោះថ្នាក់អត់? អត់
3. ចឹងថ្ងៃនេះ គ្រូនឹងប្រាប់កូនៗថា ពេលកូនៗលេងទូរសព្ទយូរពេក
   វានឹងធ្វើឱ្យភ្នែករបស់កូនឡើងក្រហមខ្លាំង និងចាប់ផ្តើមឈឺភ្នែក
   ពេលខ្លះអាចនឹងធ្វើឱ្យភ្នែករបស់កូនៗខ្វាក់បានទៀតណ៎។
4. តើកូនៗចង់លេងទូសព្ទយូរៗដែរឬទេ? អត់ទេ ព្រោះអ្វី? ខ្លាចខ្វាក់ភ្នែកអ្នកគ្រូ
5. ឥឡូវនេះ គ្រូនឹងបង្ហាញកូនៗពីរបៀបបត់កក្រដាសជារាងគ្រាប់ភ្នែក
6. ប្រាប់ពីជំហាននៃការបត់ទៅកាន់កុមារ ឬបង្ហាញពួកគេ
   បន្ទាប់មកចែកក្រដាសឱ្យកុមារបត់តាមទាំងអស់គ្នាៈ

- បត់ជារាងត្រីកោណ



- បត់ជាប្រាំបីផ្នត់ស្មើរៗគ្នា(ម្ខាង៤ផ្នត់)



- លាតចេញវិញ



- បត់ផ្ទល់មុខគ្នាឱ្យចំពាក់កណ្តាល



- ផ្ងារខ្នងឡើងលើ



- បត់មុំស្រួចទាំងពីរភ្ជួល់មុខគ្នាចំពាក់កណ្តាល

 

- បត់មុខចូលគ្នាទាំងសងខាងសម្រាប់កាន់

 

- ផ្ងារនិងលាតចេញមកវិញពាក់កណ្តាល

 

- ចាប់ផ្តើមគូរនិងផាត់ពណ៌គ្រាប់ភ្នែកនៅចំកណ្តាលភ្នែក



- បត់ចូលតាមទ្រង់ទ្រាយដើមវិញជាការស្រេច







